ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រង
# សំណួរ-ចម្លើយ
# មុខវិជ្ជា នីតិរដ្ឋធម្មនុញ្ញ

ស្រាវជ្រាវដោយ និស្សិត ឡោ គ្រឹម

ភ្នំពេញ-ឆ្នាំ២០១២

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
មហាវិទ្យាល័យ នីតិសាស្ត្រ

# នីតិរដ្ឋធម្មនុញ្ញ




1. លិខិតបទដ្ឋានគតិយុត្ត
2. **រដ្ឋធម្មនុញ្ញ**
   A. ន័យទូលាយ គឺជាវិធានច្បាប់រឹទម្លាប់ដែលកំណត់ពីទំរង់របស់រដ្ឋ ការចាត់ចែងនិងការអនុវត្តអំណាច។
   B. ន័យចង្អៀត គឺជាឯកសារដែលទាក់ទិននឹងស្ថាប័ននយោបាយ ហើយដែលត្រូវបានបង្កើតនិងកែប្រែទៅតាមនីតិវិធីដែលខុសពីនីតិវិធីក្នុងការធ្វើច្បាប់ធម្មតា។
3. **រដ្ឋធម្មនុញ្ញមានមុខងារដូចតទៅ:**
   - បង្កើតអោយមាននូវការឯកភាពជាតិទាំងមូលនៅក្នុងរដ្ឋនោះ
   - បង្កើតអោយមានប្រសិទ្ធភាពក្នុងវិស័យអប់រំ វប្បធម៌ និងសង្គមកិច្ច
   - បង្កើតអោយមាននូវព្រំដែនអំណាចដោយយោលទៅលើគោលការណ៍បែងចែកអំណាច
   - បង្កើតអោយមានទិសដៅនយោបាយក្នុងការអភិវឌ្ឍន៍ជាតិ
   - បង្កើតអោយមាននូវការធានាសិទ្ធិ និងសេរីភាពដល់ប្រជាពលរដ្ឋទាំងពីរភេទ។
4. **សន្ធិសញ្ញាអន្តរជាតិ** គឺជាការព្រមព្រៀងរវាងរដ្ឋមួយនិងរដ្ឋមួយ រដ្ឋមួយនិងរដ្ឋច្រើន រឺអង្គការអន្តរជាតិ និងសហគមន៍អន្តរជាតិណាមួយ។
5. **បទបញ្ញា**
   A. **ព្រះរាជក្រឹត្យ** ជាឈ្មោះនៃបទដ្ឋានមួយប្រភេទដែលចេញពីប្រមុខរដ្ឋនោះគឺជាព្រះមហាក្សត្រ សម្រាប់ប្រើប្រាស់ក្នុងវិស័យនីតិប្រតិបត្តិ: ទេសាភិបាល ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល PM អគ្គលេខាធិការរាជរដ្ឋាភិបាល អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ប្រតិភូរាជរដ្ឋាភិបាល អភិបាលរាជធានី ខេត្តក្រុង ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព នាយអគ្គសេនាធិការ នាយអគ្គសេនាធិការរង ឧត្តមសេនីឡើងទៅ។
   B. **អនុក្រឹត្យ** ជាលិខិតបទដ្ឋានដែលចេញដោយនាយរដ្ឋមន្ត្រីក្នុងគោលបំណងដើម្បីប្រតិបត្តិច្បាប់។ អនុក្រឹត្យត្រូវស្ថិតនៅក្នុងឋានានុក្រមក្រោមច្បាប់ ប្រសិនបើអនុក្រឹត្យផ្ទុយនឹងច្បាប់ត្រូវចាត់ទុកជាមោឃៈ។

C. **ប្រកាស** គឺជាលិខិតរដ្ឋបាលមួយប្រភេទដែលចេញដោយសមាជិករាជរដ្ឋាភិបាល ដែលជាប្រធានស្ថាប័ន។ ប្រធានស្ថាប័នរួមមានៈ រដ្ឋមន្ត្រីដែលគ្រប់គ្រងក្រសួងជំនាញ និងរដ្ឋលេខាធិការដែលគ្រប់គ្រងរដ្ឋលេខាធិការដ្ឋាន។

D. **ដីការ** ចេញមកដើម្បីធានាថែរក្សាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈក្នុងរង្វង់នៃដែនសមត្ថកិច្ចរបស់ខ្លួន។ ដីការចេញដោយអភិបាលខេត្ត រាជធានីក្រុង ឃុំសង្កាត់។

E. **សារាចរ** គឺជាអត្ថបទសម្រាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ។ អាជ្ញាធរ ដែលមានសមត្ថកិច្ចក្នុងការចេញសារាចរគឺ នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល ដែលជាប្រធានស្ថាប័ន។

F. **សេចក្តីសម្រេច** គឺជាលិខិតមួយដែលបង្ហាញអំពីអំណាចរដ្ឋបាលរបស់នាយករដ្ឋមន្ត្រី និងប្រធានស្ថាប័ន។

6. ក្រុមប្រឹក្សាធម្មនុញ្ញមានចំនួន**៩**រូបដោយ **៣**រូបតែងតាំងដោយព្រះមហាក្សត្រ ៣រូបតែងតាំងដោយរដ្ឋសភាជាតិ និង៣រូបទៀតជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយមានអាណត្តិ **៩**ឆ្នាំ។

7. ច្បាប់អាចត្រូវចាត់ថ្នាក់ជាច្រើនប្រភេទតាមធម្មតាគេធ្វើការបែងចែកច្បាប់ជា ពីរប្រភេទគឺ **ច្បាប់អង្គិនរឺច្បាប់រៀបចំអង្គការ** និង**ច្បាប់ធម្មតា**។

8. **ច្បាប់អង្គិន** គឺជាច្បាប់មួយប្រភេទដែលអនុម័តឡើងសម្រាប់បង្កើតអង្គការរឺស្ថាប័នណាមួយ ព្រមទាំងកំណត់អំពីបែបបទនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់អំណាចសាធារណៈ។

A. **ច្បាប់ធម្មតា** គឺជាច្បាប់ដែលអនុម័តដោយសភាសម្រាប់គ្រប់គ្រងសង្គមទាំងមូលអោយមានសណ្តាប់ធ្នាប់ និងដើម្បីរៀបចំនូវសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ។

9. **នីតិ** (១)គឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីច្បាប់។ (២)គឺជាសំណុំវិធានទាំងអស់ដែលសម្រាប់គ្រប់គ្រងការរស់នៅក្នុងសង្គម។ បានជាគេបង្កើតច្បាប់ ព្រោះគេយកច្បាប់នោះដើម្បីគ្រប់គ្រងមនុស្សនៅក្នុងសង្គម។ ដូច្នេះ នីតិមានមុខងា ៣ចំនុចសំខាន់ៗដូចតទៅៈ

- ដែលចង្អុលបង្ហាញពីរបៀបរបទង្វើនៃអំពើរបស់សមាជិកសង្គមមួយ
- ដែលសមាជិកទាំងអស់ត្រូវតែគោរព និងអនុវត្តតាមទាំងស្រុង
- ហើយការអនុវត្តនេះត្រូវបានធានាដោយអំណាចរដ្ឋ។

10. **ច្បាប់** គឺជាលិខិតបទដ្ឋានគតិយុត្តដែលអនុម័តដោយ សភាមួយ ឬសភាទាំងពីរនៃអង្គនីតិបញ្ញត្តិដូចជាសហសភាជាដើម ។

11. **ចលនាវត្ថុពីកំណើត** ជាទ្រព្យដែលអាចអោយគេផ្លាស់ទីបានយ៉ាងងាយស្រួល។

12. **នីតិវត្ថុវិស័យ** គឺជាបណ្តាវិធានផ្នែកអាកប្បកិរិយាទាំងឡាយណាដែលគ្រប់គ្រងទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ហើយដែលត្រូវបានគេបង្កើតឡើងនឹងមានទណ្ឌកម្មដែលធានាដោយអាជ្ញាធររដ្ឋ។

13. **នីតិអត្តវិស័យ** គឺជាសិទ្ធិអំណាចដែលបុគ្គលម្នាក់ៗមាន។

14. **នីតិវិជ្ជមាន រឺនីតិជាក់ស្តែង** គឺជាវិធានច្បាប់ទាំងឡាយណាដែលកំពុងតែស្ថិតនៅជាធរមានក្នុងសង្គមណាមួយ និងនៅក្នុងពេលវេលាណាមួយជាកំណត់។

15. **វិធាននីតិ** គឺជាវិធានផ្នែកអាកប្បកិរិយារបស់មនុស្ស ដែលតាមរយៈវិធាននេះ គឺសង្គមជាអ្នកចាប់បង្ខំអោយគោរពប្រសិនបើយើងមិនគោរពដោយខ្លួនឯង។

16. ចរឹតលក្ខណៈសំគាល់របស់វិធាននីតិមាន៣ គឺ ទូទៅ អរូបី ដាច់ខាត។

17. ចរិតលក្ខណៈទូទៅ រឺមិនចំពោះ មានន័យថាវិធាននីតិបង្កើតមកសម្រាប់អនុវត្តជនគ្រប់រូប មិនសំដៅទៅលើបុគ្គលណាមួយនោះទេ។
18. **ប្រភពរបស់វិធាននីតិមាន:**
    - ច្បាប់
    - ទំនៀមទម្លាប់
    - យុត្តិសាស្រ្ត(មិនមែនជាវិធានរបស់នីតិទេ)
    - លទ្ធិ
19. **ទំនៀមទម្លាប់** គឺជាវិធានដែលកើតចេញពីការប្រើប្រាស់ជាទូទៅក្នុងរយៈពេលដ៏យូរអង្វែង និងចេញពីជំនឿដែលគេថាមានទណ្ឌកម្មប្រសិនបើមិនគោរពទំនៀមទម្លាប់ប្រើប្រាស់។
20. **យុត្តិសាស្រ្ត** គឺជាសេចក្តីសម្រេចរបស់តុលាការ(យុត្តិសាស្រ្តមិនមែនជាវិធានរបស់នីតិទេ)។
21. **លទ្ធិ** គឺជាគំនិតយោបល់ទាំងឡាយរបស់អ្នកច្បាប់ ជាពិសេសសាស្រ្តាចារ្យនៃសាកលវិទ្យាល័យនានា ចៅក្រម រឺមេធាវី .... ។
22. ប្រភាពរបស់វិធាននីតិមាន ២ គឺ ច្បាប់ និងទំនៀមទម្លាប់។
23. **នីតិឯកជន** គឺជាវិធាននីតិដែលគ្រប់គ្រងនូវរាល់ទំនាក់ទំនង រវាងបុគ្គលឯកជននិងបុគ្គលឯកជន រឺបុគ្គលឯកជន និងសមហភាពឯកជន(ដូចជា ក្រុមហ៊ុន រឺសមាគមន៍ជាដើម)។
24. **នីតិរដ្ឋប្បវេណី** គឺជាវិធានដែលអនុវត្តន៍ទៅលើទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គឯកជន។ ពាក្យថាបុគ្គលអាចជារូបវ័ន្តបុគ្គល រឺនីតិបុគ្គល។
25. **រូបវន្តបុគ្គល** មនុស្សលោក ដែលផ្ទុយពីមនុស្ស សិប្បនិមិត្តឬប្រឌិតដូចជាសាជីវកម្ម ជាដើម។
26. **នីតិបុគ្គល** ជាអង្គភាពដែលមិនមិនមែនជាមនុស្ស ឬជាអង្គការមួយដែលច្បាប់ឲ្យនិយមន័យយ៉ាងច្បាស់ហើយចាត់ទុកថាជា "បុគ្គល" សំរាប់គោលបំណងនៃច្បាប់នោះតែប៉ុណ្ណោះ។ ឧទាហរណ៍៖ ច្បាប់សាជីវកម្មទំនើបតែងតែឲ្យនិយមន័យ និងចាត់ទុកសាជីវកម្មទាំងឡាយជានីតិបុគ្គល។
27. **នីតិកាតព្វកិច្ច** គឺទំនាក់ទំនងគតិយុត្តិដែលចង់បុគ្គលពីរនាក់ ដោយអោយបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ បុគ្គលដែលមានករណីយកិច្ចហៅថា **កូនបំណុល** រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចហៅថាម្ចាស់បំណុល។
28. **នីតិពាណិជ្ជកម្ម** គឺជាវិធានដែលអនុវត្តទៅលើពាណិជ្ជកម្មក្នុងការធ្វើពាណិជ្ជកម្ម។
29. **នីតិការងារ** ជាវិធានដើម្បីគ្រប់គ្រងរាល់សកម្មភាពរបស់ម្ចាស់សហគ្រាស និងពលករពោលគឺ គ្រប់គ្រងទំនាក់ទំនងរវាងវិនិយោជិត និងកម្មករនិយោជិត។
30. **នីតិព្រហ្មទណ្ឌ** គឺជាសំណុំវិធានទាក់ទងនឹងទោសអំពើដែលត្រូវទទួលទោសនេះ និងគ្រប់អ្វីៗដែលទាក់ទងទៅនឹងការបង្រ្កាបអំពើល្មើសទាំងនេះ។
31. **ក្រៅពីនីតិរដ្ឋប្បវេណី** ក្នុងនីតិឯកជននៅមាន នីតិពាណិជ្ជកម្ម នីតិព្រហ្មទណ្ឌ នីតិការងារ នីតិនីតិវិធីនីតិអន្តរជាតិ ឯកជន...។
32. នីតិនិរភ័យសង្គម គឺជាវិធាននីតិដែលកំណត់ពីទំនាក់ទំនងរវាងសន្តិសុខសង្គមជាមួយអ្នកដែលគេរ៉ាប់រងដូចជាពេលដែលមានជំងឺឈឺស្កាត់ គ្រោះថ្នាក់ការងារ រឺគ្រោះថ្នាក់ចរាចរណ៍។

33. នីតិអន្តរជាតិឯកជន គឺជាវិធានសម្រាប់គ្រប់គ្រងបុគ្គលឯកជននៅរាល់ទំនាក់ទំនងទាំងឡាយណាដែលពាក់ព័ន្ធនឹងបរទេស។ បរទេសអាចជាបុគ្គលឯកជន រឺហេតុនឹងអំពើដែលបានកើតឡើងនៅឯបរទេស។
34. **នីតិសាធារណៈ** គឺជាវិធានដែលគ្រប់គ្រងនូវរាល់ទំនាក់ទំនងរបស់ស្ថាប័នរដ្ឋដូចជា ទំនាក់ទំនងរវាងភ្នាក់ងាររដ្ឋជាមួយឯកជន។
35. **នីតិរដ្ឋធម្មនុញ្ញ** គឺជាវិធានច្បាប់គតិយុត្តទាំងឡាយ ដែលទាក់ទងទៅនឹងរបៀបរបបគ្រប់គ្រងរដ្ឋ(សាធារណៈរដ្ឋ ឬរាជានិយម) ដោយមានការរៀបចាត់តាំងជាអង្គការរដ្ឋនានា (ដូចជា រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងៗទៀត) និងមានកំណត់អំពីរបៀបគ្រប់គ្រងអំណាចសាធារណៈ ព្រមទាំងមានសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋ។
36. **នីតិរដ្ឋបាល** គឺជាវិធានទាំងឡាយណាសម្រាប់រៀបចំផ្នែករដ្ឋបាលសាធារណៈ អោយមានការបែងចែកអំណាចទៅតាមស្ថាប័នរដ្ឋនានា ព្រមទាំងការធ្វើទំនាក់ទំងរដ្ឋបាល និងរាស្ត្រ។
37. **នីតិហិរញ្ញវត្ថុ** គឺជាវិធានដែលកំណត់ពីចំណាយ ចំណូលរបស់ស្ថាប័នរដ្ឋ និងអង្គការសាធារណៈដទៃទៀត។
38. **នីតិអន្តរជាតិសាធារណៈ** គឺជាវិធានដើម្បីគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋទាំងឡាយ និងអង្គការអន្តរជាតិដទៃទៀត។
39. ប្រព័ន្ធច្បាប់Common Low ចាប់កំណើតនៅឆ្នាំ១០៦៦ នៃគ.ស នៅចក្រភពអង់គ្លេស ហើយប្រព័ន្ធនេះបានរីករាលដាលដល់បណ្តាប្រទេសមួយចំនួនទៀតដូចជា អៀកឡង់ អាមេរិក កាណាដា អូស្ត្រាលី ណូវ៉េសឺឡង់ និងបណ្តាប្រទេសមួយចំនួនទៀតនៅទ្វីបអាស៊ី និងអាព្រិច។ ប្រព័ន្ធច្បាប់Common Low រួមមាន នីតិអង់គ្លេស និងនីតិនៃបណ្តាប្រទេសដែលធ្លាប់ជាសមាជិក Common Weath ។
40. ប្រព័ន្ធច្បាប់សង្គមនិយមមានដើមកំណើតពីបដិវត្តន៍ខែតុលា ឆ្នាំ១៩១៧ នៅសហភាពសូវៀត ដែលមុនពេលនេះបណ្តាប្រទេសនៃសហភាពសូវៀត ជាប្រទេសកាន់ប្រព័ន្ធច្បាប់Civi low។
41. នៅឆ្នាំ១៩៨០ ក្រោមឥទ្ធិពលនៃកំណែទម្រង់Perestroika បានកំណត់នូវសមភាពរវាងកម្មសិទ្ធិ ៣យ៉ាងគឺ កម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព និងកម្មសិទ្ធិរដ្ឋ។ នៅថ្ងៃទី ២១.១២ ឆ្នាំ១៩៩០ សហភាពសូវៀតត្រូវបានបញ្ចប់បច្ចុប្បន្ននេះ គេឃើញនៅសល់តែប្រទេស ចិន កូរ៉េខាងជើង វៀតណាម... ដែលនៅពេលបន្តប្រើប្រាស់ច្បាប់សង្គមនិយម ប៉ុន្តែមាននិន្នាការកែទម្រង់ឈានទៅរកសេដ្ឋកិច្ចទីផ្សារ។
42. ដើម្បីអោយច្បាប់មួយចេញមកអនុវត្តបានត្រឹមត្រូវមានលក្ខខណ្ឌ ២យ៉ាង:

    A. ន័យកត្តៈ

    -ការផ្សព្វផ្សាយរបស់អាជ្ញាធរមានសមត្ថកិច្ច

    -ការយល់ដឹងរបស់ប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយច្បាប់

    B. ន័យគតិយុត្ត

    -ការបញ្ជូនច្បាប់ទៅអោយព្រះមហាក្សត្រ

    -រង់ចាំរយៈពេលចូលជាធរមានរាជធានីភ្នំពេញ១០ថ្ងៃ ទូទាំងប្រទេស២០ថ្ងៃ (ប្រញាប់ចូលភ្លាម)
43. **ច្បាប់អង្គិន**

    រឺច្បាប់រៀបចំអង្គការមុននឹងត្រូវបានប្រកាសអោយប្រើដោយព្រះមហាក្សត្រដាច់ខាតត្រូវបញ្ជូនទៅអោយក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យពីធម្មនុញ្ញភាពរបស់ច្បាប់នោះសិន ផ្ទុយមកវិញច្បាប់ធម្មតាមិនចាំបាច់ទេ

ប៉ុន្តែនៅពេលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់
ប្រជាពលរដ្ឋមានសិទ្ធិប្តឹងពីធម្មនុញ្ញភាពតាមរយៈតំណាងរបស់ប្រពលរដ្ឋ និងតុលាការ។

44. **និរាករណ៍នៃច្បាប់** ជាគោលការច្បាប់មានអនុភាពអនុវត្តជារឿងរហូតតែគេឃើញមានច្បាប់មួយចំនួនគឺអនុវត្តក្នុងពេលវេលាណាមួយជាកំណត់។

45. **និរាករណ៍** គឺជាការលុបចោលនូវវិធានច្បាប់ រឺបទបញ្ញាលែងអោយមានអនុភាពអនុវត្តតទៅទៀត។ និរាករណ៍ត្រូវបែងចែកជា ៣ប្រភេទគឺនិរាករណ៍ដោយ ជាក់លាក់រឺលាយល័ក្ខអក្សរ ដោយតុណ្ហភាពរឺស្ងៀមស្ងាត់ដោយឯកឯង។

46. **និរាករណ៍ដោយជាក់លាក់ រឺលាយល័ក្ខអក្សរ** ជានិរាករណ៍មួយប្រភេទដែលច្បាប់ថ្មីចេញមកជំនួសច្បាប់ណាមួយដោយចែងយ៉ាងច្បាស់លាស់ថា វាមកជំនួសអោយទៅច្បាប់ចាស់ណាមួយនោះ។

47. **និរាករណ៍តុណ្ហភាព រឺស្ងៀមស្ងាត់** ជានិរាករណ៍មួយប្រភេទដែលច្បាប់ថ្មីមិនបានកំណត់ថាវាចេញមកជំនួសអោយច្បាប់ចាស់ណាមួយនោះទេ ប៉ុន្តែជាគោលការណ៍នៅពេលដែលមានច្បាប់២ចែងខុសគ្នាអំពីបញ្ហាតែមួយ គឺគេចាត់ទុកច្បាប់ណាដែលមានការបរិច្ឆេទថ្មីជាងគេទុកថាត្រឹមត្រូវ។

48. **និរាករណ៍ដោយឯកឯង**
គឺជានិរារណ៍មួយប្រភេទដែលខ្លឹមសារនៃច្បាប់នោះមិនទាក់ទងនិងការរីកចំរើនរបស់សង្គម ឬមានលក្ខណៈចាស់ហួសសម័យទៅហើយ ហើយគ្មានបទបញ្ញត្តិណាមួយមកនិរាករណ៍ដោយជាក់លាក់ឬស្ងៀមស្ងាត់នោះទេ។

49. ច្បាប់ថ្មីមិនត្រូវអនុវត្តទៅលើការបង្កើតរាប់ការបញ្ចប់ស្ថានភាពគតិយុត្តដែលកើតមានមុនច្បាប់នេះចូលជាធរមាន។ អញ្ញត្រកម្មទៅនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មីច្បាប់ដែលអាចនឹងអនុវត្តទៅលើស្ថានភាពគតិយុត្តដែលមានតាំងពីអតីតកាល។

50. **ចំពោះរឿងព្រហ្មទណ្ឌ** នៅពេលដែលមានច្បាប់ថ្មីស្រាលជាងច្បាប់ចាស់ពេលនេះគេយកច្បាប់ថ្មីមកប្រើទោះជាអំពើប្រព្រឹត្តបានមុនពេលច្បាប់នេះចូលជាធរមានក៏ដោយ។

51. **បវេណី** គឺជាវិធានដែលមានប្រភពចេញពីទំលាប់ប្រើប្រាស់ជាទូទៅ ក្នុងរយៈពេលដ៏យូរអង្វែង និងចេញពីជំនឿដែលគេថា មានទណ្ឌកម្មប្រសិនបើមិនគោរព ទំនៀមទំលាប់ប្រើប្រាស់នោះទេ។

52. ដើម្បីកំណត់អោយបានច្បាស់ពីឋានៈរបស់បវេណីយើងត្រូវធ្វើការសិក្សាពីទំនាក់ទំនងរវាងបវេណី និងច្បាប់ដែលជាប្រភពចំបងរបស់នីតិនៅក្នុងប្រព័ន្ធច្បាប់Civil low។

53. យុត្តិសាស្ត្រ
   A. ន័យទូលាយ គឺជាបណ្តាលសេចក្តីទាំងឡាយរបស់តុលាការ។
   B. ន័យចង្អៀត ជាសេចក្តីសម្រេចរបស់តុលាការ លើបញ្ហាច្បាប់ណាមួយដែលមានលក្ខណៈស៊ីសង្វាក់គ្នាគ្រប់គ្រាន់។

54. ជាគោលការណ៍ សេចក្តីសម្រេចរបស់តុលាការមិនអាចបង្កើតជាច្បាប់ទេ ព្រោះចៅក្រមពុំមានតួនាទីក្នុងការបង្កើតច្បាប់។ ចៅក្រមមានតួនាទីត្រឹមតែជាអ្នកបកស្រាយ និងអនុវត្តច្បាប់ប៉ុណ្ណោះ។

55. ដើម្បីក្លាយជាវិធាននៃនីតិសេចក្តីសម្រេចត្រូវមានលក្ខណៈ ៣យ៉ាងគឺ ត្រូវសរសេរជាពាក្យទូទៅ សេចក្តីសម្រេចរបស់តុលាការត្រូវធ្វើឧភាសកម្ម សេចក្តីសម្រេចរបស់តុលាការមានលក្ខណៈដូចគ្នា។

56. **នីតិអត្តវិស័យ** គឺជាសិទ្ធិអំណាចដែលនីតិវត្ថុនីស័យទទួលស្គាល់ជនណាម្នាក់ និងដើម្បីជាប្រយោជន៍ចំពោះបុគ្គលនោះផ្ទាល់។
57. គេអាចធ្វើការចាត់ថ្នាក់នៃសិទ្ធិទាំងឡាយរបស់បុគ្គលបានដោយផ្អែកលើសញ្ញាណនៃ**បេតិកភណ្ឌ** ។
58. បេតិកភណ្ឌ
    - A. ន័យធម្មតា ជាទ្រព្យទាំងឡាយរបស់បុគ្គល។
    - B. ន័យគតិយុត្ត គឺជាបណ្តាទ្រព្យនិងកាតព្វកិច្ចទាំងឡាយដែលគេចាត់ទុកជាបណ្តុំសកលមួយដែលនៅក្នុងនោះគេឃើញមានទាំង ទ្រព្យសកម្ម និងទ្រព្យអកម្មនៅលាយឡំគ្នា។
59. សិទ្ធិក្រៅពីបេតិកភណ្ឌ គឺជាសិទ្ធិទាំងឡាយណាដែលសំដៅទៅលើការការពារផលប្រយោជន៍ផ្នែកស្មារតីរបស់បុគ្គល។ លក្ខណៈសំគាល់នៃសិទ្ធិនេះរួមមាន ពុំអាចគិតជាប្រាក់បាន ពុំអាចធ្វើអនុប្បទាន(ផ្ទេរ) ពុំអាចផ្ទេរបាន គ្មានអាជ្ញាយុកាល ពុំអាចរឹបអូសបាន។
60. សិទ្ធិគ្រួសារ គឺជាសិទ្ធិដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងនៅក្នុងក្រុមគ្រួសារដែលរួមមាន ឪពុកម្តាយ មាមីង បងប្អូន ជីដូនជីតា(ញាតិការទាំង៧សណ្តាន)។
61. អំណាចមេបា គឺជាសិទ្ធិគ្រប់គ្រងកូនដែលច្បាប់ទទួលស្គាល់នៅពេលគេរៀបការស្របច្បាប់។ ទោះបីជាមានអំណាចសម្រេចពីតុលាការក៏ដោយ សិទ្ធិនោះអាចនឹងបាត់បង់នៅពេលដែរៈ ខ្វះខាតក្នុងការអប់រំកូន វាយធ្វើបាបកូនឥតត្រាប្រណី ប្រព្រឹត្តផ្ទុយសីលធម៌ដែលបណ្តាលអោយជះឥទ្ធិពលអាក្រក់ដល់កូន ប្រើឧបាយកលផ្សេងៗដើម្បីបង្ខំកូនអោយប្រព្រឹត្តអ្វីមួយដែលប៉ះពាល់ដល់សង្គម។
62. អ្នកដែលមានសិទ្ធិប្តឹងអំពីអំណាចមេបាន គឺៈ អង្គការរដ្ឋ អង្គការមហាជន ព្រះរាជអាជ្ញា ញាតិលោហិត។
63. **នីតិវិធី** វិធាននិងវិធីនៃកិច្ចដំនើរការនៃ បណ្តឹងមួយដោយរាប់បញ្ចូលទាំង ការជជែកក្តី, វិធានផ្សេងៗ, ការបង្ហាញភស្តុតាង, និងការប្រតិ បត្តិតាមច្បាប់។
64. សមាជិករដ្ឋសភាមាន ២ប្រភេទគឺ
    - សមាជិករដ្ឋសភាសុទ្ធ (សុទ្ធតែមានមុខងារក្នុងគណៈកម្មាធិការទាំង៩)
    - សមាជិករដ្ឋសភាផង និងសមាជិករាជរដ្ឋាភិបាលផង(សមាជិកគណៈរដ្ឋមន្ត្រី)។
65. បេក្ខភាពនាយករដ្ឋមន្ត្រីតាមរយៈ
    - ជាតំណាងរាស្ត្រនៅក្នុងមណ្ឌលបោះឆ្នោតណាមួយ
    - ស្ថិតក្នុងគណបក្សដែលជាប់ឆ្នោត។
66. រដ្ឋធម្មនុញ្ញដើមអាចបង្កើតឡើងដោយ
    - ប្រជាមតិ(អោយប្រជាពលរដ្ឋសម្រេចដោយផ្ទាល់ ឧ.ប្រទេសស្វីស)
    - សភាធម្មនុញ្ញ(ឈរលើគោលការណ៍ ២ភាគ៣)។
67. កត្តាដែលនាំអោយធ្វើវិសោធនកម្មរួមមានៈ ដើម្បីកែលំអរ ការវិវត្តន៍សង្គម បច្ចេកវិទ្យា វិទ្យាសាស្ត្រ នយោបាយ ការកំណត់សិទ្ធិអំណាច ពេលវេលា កាលៈទេសៈ ហួសសម័យ មិនបម្រើអោយផលប្រយោជន៍ប្រជាជន សង្គម មិនឆ្លុះបញ្ចាំងអំពីតម្លៃ និងអធិបតេយ្យភាពជាតិសង្គម ....។
68. រដ្ឋសភាមាអាណត្តិ ប៉ុន្តែរដ្ឋាភិបាលឥតមានអាណត្តិទេ។
69. ការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញភាពចាំបាច់ដូចជាៈ
    - ពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់អ្នកទាំងនោះ

- ពាក់ព័ន្ធនឹងនយោបាយ
- ការបកស្រាយច្បាប់
- ការពិនិត្យធម្មនុញ្ញភាព
- ដោះស្រាវិវាទទាក់ទងនឹងការបោះឆ្នោត
  - ការចុះឈ្មោះ
  - ការបង្កើតគណបក្ស
  - ការបញ្ចូលគណបក្ស
  - អ្នកត្រូវបោះឆ្នោត។

70. បណ្ដឹងទាក់ទងនឹងការបោះឆ្នោតត្រូវដាក់អោយក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកដោះស្រាយ មូលហេតុដែលមិនអោយតុលាការដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោត ព្រោះមកវិវាទនេះមិនអាចពន្យាពេលបានទេ ពោលគឺការដោះ ស្រាយត្រូវអោយបានរហ័សរយៈពេល ១០ទៅ២០ថ្ងៃយ៉ាងយូរ (អ្នកទាំងនោះគឺជាអ្នកបច្ចេកទេស)។

71. -សម្លេងភាគច្រើនដាច់ខាត 50%+1 គឺ120/2=60+1

-សម្លេង2/3 =120x2/3

-មតិភាគច្រើនដោយប្រៀប គឺ 60ទល់60យកសម្លេងប្រធាន (ប្រធានមានឧត្តមភាព)។

72. កិច្ចព្រមព្រៀងទីក្រុងប៉ារីសរវាងភាគីជម្លោះ ខ្មែរទាំង ៤ (ខ្មែរនៅភ្នំពេញ បក្សហ៊្វុនស៊ិនប៉ិច បក្សស៊ឺនសាន បក្សកម្ពុជាប្រជាធិបតេយ្យ) ថ្ងៃទី២៣ តុលា ១៩៩១ បាននាំមកនូវរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្សមានឆន្ទៈពិតៗ ប្រជាពលរដ្ឋខ្មែរស្ទើតែ ៩០ % នៃចំនួនជាង ៤លាន ៧សែននាក់ ដែលបានទៅបោះឆ្នោត ដើម្បីជ្រើសរើសតំណាងរបស់ខ្លួនដោយស្របច្បាប់ ដោយសេរី និងយុត្តិធម៌។

73. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួមមាន:

- ព្រះមហាក្សត្រ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ប្រធានតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ប្រធានសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- និង ចៅក្រម ៣រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម

74. តាមរដ្ឋធម្មនុញ្ញ អ្នកដែលមានសិទ្ធិផ្ដួចផ្ដើមគំនិតសើរើ ឬផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺមានព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា និងតាមសេចក្ដីស្នើរបស់តំណាងរាស្ត្រ1/4 ឬសមាជិកព្រឹទ្ធសភា1/4។

75. **រដ្ឋធម្មនុញ្ញ** ជាច្បាប់រៀបចំអង្គការនិងជាច្បាប់ គ្រឹះរបស់ប្រទេសជាតិឬរដ្ឋមួយ ដែលអាចជាលាយលក្ខណ៍អក្សរ ឬគ្មានសរសេរ ម្យ៉ាងវិញទៀតរដ្ឋធម្មនុញ្ញចែងពី សិទ្ធិសេរីភាពប្រជាពលរដ្ឋ សេដ្ឋកិច្ច វប្បធម៌ ការអប់រំ របបនយោបាយ ការបែងចែកអំណាច អធិបតេយ្យភាព ឯករាជ្យភាពនៃប្រទេស ជំនឿសាសនា ... ។

76. **រដ្ឋធម្មនុញ្ញមានមុខងារដូចតទៅ:**

- បង្កើតអោយមាននូវការឯកភាពជាតិទាំងមូលនៅក្នុងរដ្ឋនោះ
- បង្កើតអោយមានប្រសិទ្ធិភាពក្នុងវិស័យអប់រំ វប្បធម៌ និងសង្គមកិច្ច...
- បង្កើតអោយមានព្រំដែនអំណាចដោយយោងទៅលើគោលការណ៍បែងចែកអំណាច
- បង្កើតអោយមានទិសដៅនយោបាយក្នុងការអភិវឌ្ឍជាតិ
- បង្កើតអោយមាននូវការធានាសិទ្ធិ និងសេរីភាពដល់ពលរដ្ឋទាំងពីរភេទ។

77. ក្រុមប្រឹក្សាព្រះរាជាណាចក្ររួមមានៈ
- ព្រះមហាក្សត្រទ្រង់ចាត់តាំង ២រូប
- តំណាងភូមិភាគ ៨រូប
- តំណាងអាជីវករ ១០រូប
- និងតំណាងអ្នករាជការ ៤រូប។

78. សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពទាំងអស់នៅក្នុងមុខងារសាធារណៈ និងមុខងារជា
- សមាជិករាជរដ្ឋាភិបាល
- សមាជិកព្រឹទ្ធសភា
- សមាជិករដ្ឋសភា
- ប្រធាន អនុប្រធានសហជីព
- ប្រធាន អនុប្រធាន គណបក្សនយោបាយ និង
- ចៅក្រមក្នុងមុខតំណែង

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកមកពីៈ
- ព្រះមហាក្សត្រតែងតាំង ៣រូប
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជ្រើសតាំង ៣រូប
- រដ្ឋសភា បោះឆ្នោតជ្រើតាំង ៣រូប
- សមាសភាពអ្នកមានសិទ្ធិដាក់សំណើរសុំពិនិត្យធម្មនុញ្ញភាពរួមមាន ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី តំណាងរាស្ត្រ១/១០ សមាជិកព្រឹទ្ធសភា១/៤ តុលាការ និងប្រជារាស្ត្រ (ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា តំណាងរាស្ត្រ១/១០ សមាជិកព្រឹទ្ធសភា១/៤ តុលាការ)។

79. **បទល្មើសព្រហ្មទណ្ឌ** កំហុសដែលរដ្ឋាភិបាលបានសំរេច ថាជាការបណ្តាលអោយខូចខាត ឬរំលោភ សាធារណៈហើយដូច្នោះជាកំហុសដែលអាចនឹងយកទៅប្តឹងបាននៅក្នុងដំណើរការជំរះក្តីព្រហ្មទណ្ឌ ។ ចែកចេញជា ៣ប្រភេទគឺៈ
- បទលហុ(មានរយៈពេល ៦ថ្ងៃ ចុះក្រោម)
- បទមជ្ឈិម(មានរយៈពេល ៦ថ្ងៃដល់ ៥ឆ្នាំ)
- បទឧក្រិដ្ឋ(មានរយៈពេល ៥ឆ្នាំដល់ ៣០ឆ្នាំ)

80. ដែលហៅថា បទល្មើសបានទាល់តែមានធាតុផ្សំ ៣ចូលរួមដោយមិនអាចខ្វះធាតុណាមួយបានឡើយ ពោលគឺៈ
- **ធាតុនីត្យានុកូល** គឺជាធាតុច្បាប់(អំពើទាំងឡាយណាដែលច្បាប់បានចែង)
- **ធាតុសត្យានុម័ត** គឺជាធាតុសម្ភារៈ ធាតុជាក់ស្តែង

– **ធាតុអត្តនោម័ត** គឺជាធាតុចិត្តសាស្ត្រ ឬផ្លូវចិត្ត(តើវាប្រព្រឹត្តដោយចេតនា ឬអចេតនា)។